សូមជម្រាបសួរ នេះជាការពិពណ៌នាអំពីសាលាវិទ្យាល័យរបស់ខ្ញុំ។
សាលាវិទ្យាល័យរបស់ខ្ញុំគឺស្ថិតនៅឆ្ងាយពីផ្ទះ។ កាលពីមុនខ្ញុំបានរៀននៅសាលាបឋមសិក្សា ពីថ្នាក់ទី ១ រហូតដល់ថ្នាក់ទី ៥ ហើយសាលាបឋមសិក្សារបស់ខ្ញុំគឺនៅក្បែរផ្ទះ។
ដែលខ្ញុំតែងតែធ្វើដំណើរពីផ្ទះទៅកាន់សាលាបឋមសិក្សាពីថ្នាក់ទី ១ រហូតដល់ថ្នាក់ទី ៥។
ហើយពេលដែលខ្ញុំបញ្ចប់នៅក្នុងសាលាបឋមសិក្សា របស់ខ្ញុំ។
ខ្ញុំត្រូវបន្តការសិក្សាទៅថ្នាក់វិទ្យាល័យ ដែលថ្នាក់វិទ្យាល័យនៅក្នុងភូមិមួយផ្សេងទៀត
ហើយដែលត្រូវរៀនពីថ្នាក់ទី ៦ រហូត[?]ដល់ថ្នាក់ទី ១២។ ហើយវិទ្យាល័យរបស់ខ្ញុំគឺនៅឆ្ងាយពីផ្ទះ
គឺមានចំងាយរហូតដល់ ៧ គីឡូម៉ែត្រ។ [...] មានចំងាយឆ្ងាយ
ហើយវាមិនអាចធ្វើដំណើរដោយថ្មើរជើងបាននោះទេ។ ហើយពេលដែលខ្ញុំទៅសាលា
នេះគឺជាការចាប់ផ្ដើមនៃការដែលខ្ញុំត្រូវធ្វើដំណើរដោយកង់។
អញ្ចឹងគឺឪពុកម្ដាយរបស់ខ្ញុំបានទិញកង់ថ្មីឲ្យខ្ញុំមួយ នៅពេលដែលខ្ញុំចប់ បញ្ចប់ថ្នាក់បឋមសិក្សា
គឺខ្ញុំជិះកង់ទៅសាលាវិទ្យាល័យរបស់ខ្ញុំ ដោយសារសាលាវិទ្យាល័យរបស់ខ្ញុំមានចំងាយរហូតទៅដល់ ៧ គីឡូម៉ែត្រ។
ដូច្នេះហើយគឺខ្ញុំមិនអាចធ្វើដំណើរដោយថ្មើរជើងទៅកាន់វិទ្យាល័យរបស់ខ្ញុំបាននោះទេ។
ហើយមធ្យោបាយធ្វើដំណើររបស់ខ្ញុំគឺខ្ញុំជិះកង់។
ហើយការជិះកង់របស់ខ្ញុំដែលមានរយៈចំងាយប្រហែលជា ៧ គីឡូម៉ែត្រនោះ
គឺចំណាយពេលប្រហែលជា ៤០ នាទី ដែលខ្ញុំជិះធ្វើដំណើរដោយកង់។ អញ្ចឹង
គឺជាការផ្លាស់ប្ដូរមួយយ៉ាងខ្លាំងពី [...] ពីថ្នាក់បឋមសិក្សា ហើយប្ដូរទៅកាន់ថ្នាក់វិទ្យាល័យ
គឺភាពខុសប្លែកទី ១ នោះ គឺរយៈចំងាយដែលសាលាស្ថិតនៅឆ្ងាយពីផ្ទះ ត្រូវធ្វើដំណើររយៈពេលយូរ
ហើយត្រូវធ្វើដំណើរដោយមធ្យោបាយជិះយន្តជំនិះ គឺជិះកង់ពីផ្ទះទៅសាលារៀន
ហើយមួយទៀតគឺសាលាគឺក៏លក្ខណៈខុសគ្នាដែរ។
សាលាដែលខ្ញុំធ្លាប់រៀននៅបឋមសិក្សាគឺអាគារកាលពីខ្ញុំនៅរៀន គឺអាគារឈើ
ហើយអាគារនឹងគឺអាគារឈើ ហើយអត់មានជញ្ជាំងត្រឹមត្រូវនោះទេ ជញ្ជាំងធ្វើអំពីពេលខ្លះស្លឹកដូង។
ហើយពេលដែលខ្ញុំបន្តទៅសាលាវិទ្យាល័យគឺសាលាគឺធំជាងពីមុន
អញ្ចឹងគឺវិទ្យាល័យរបស់ខ្ញុំគឺស្អាតជាង ហើយមានមនុស្សច្រើនជាង គឺអាគារនោះគឺធ្វើពីថ្ម
ហើយមានសួនច្បារ មានដើមឈើនៅក្នុងសាលារៀន ហើយមានកង់ជាច្រើនដែលសិស្សទាំងអស់
សិស្សានុសិស្សទាំងអស់ ទាំងសិស្សប្រុស ទាំងសិស្សស្រី ភាគច្រើនគឺជិះកង់ទៅសាលារៀនដូចគ្នា
ដូចខ្ញុំដែរ។ ហើយមានសិស្សតែមួយចំនួនដែលផ្ទះរបស់ពួកគាត់ស្ថិតនៅក្បែរសាលារៀន
ហើយគាត់អាចដើរទៅកាន់វិទ្យាល័យបានដូចដែរ។ ហើយចំណែកខ្ញុំគឺត្រូវធ្វើដំណើរដោយជិះកង់
ហើយសាលារបស់ខ្ញុំគឺធំជាងពីមុន មានមនុស្សច្រើនជាងពីមុន គឺមានសិស្សច្រើនជាងពីមុន
មានកង់ជាច្រើនដែលចតនៅក្នុងសាលារៀន។ ហើយទីធ្លាក៏ធំជាងពីមុនដែរ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ហើយមានសិស្សជាច្រើននៅក្នុងថ្នាក់វិទ្យាល័យ។
ហើយខ្ញុំក៏សូមបញ្ចប់ការពិពណ៌នាទៅលើសាលាវិទ្យាល័យរបស់ខ្ញុំនេះដោយប៉ុណ្ណេះដែរ។
សូមអរគុណ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.